ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិជនពិការ
គណៈកម្មាធិការលទ្ធកម្ម
លេខ : ០០៣..... មជព/គលក

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
ចូល
លេខ......0512......
ថ្ងៃទី...31.01.19..ម៉ោង..11:00..
បញ្ជូន.......

ការិយាល័យរដ្ឋបាល ក្រ.សហវ
មកដល់ថ្ងៃទី 29.01.19 ម៉ោង 10:30
លេខ: 237 C
អ្នកទទួល:.......ហត្ថលេខា.......
អ្នកប្រគល់:.......ហត្ថលេខា.......
បញ្ជូនទៅ:.......

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃលើការផ្គត់ផ្គង់ សម្ភារផ្គត់ផ្គង់សម្អាតនិងអនាម័យ សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា សង្ហារឹម សម្ភារប្រើប្រាស់ និងសម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា និងសម្ភារការិយាល័យ ជូនមូលនិធិជនពិការ សម្រាប់ឆ្នាំ២០១៩

មូលនិធិជនពិការ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា មូលនិធិជនពិការ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សម្ភារដូចខាងក្រោម ៖

- សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ
- សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា សង្ហារឹម សម្ភារប្រើប្រាស់ និងសម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា
- សម្ភារការិយាល័យ

មូលនិធិជនពិការ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃមូលនិធិជនពិការ ដែលមានអាសយដ្ឋានផ្លូវលេខ៦អា សង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ ចាប់ពីថ្ងៃសុក្រ ៥រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ រៀងរាល់ម៉ោងធ្វើការ។

ឯកសារដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុត ត្រឹមថ្ងៃចន្ទ ៦រោច ខែមាឃ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង៩:00 នាទីព្រឹក។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅមូលនិធិជនពិការ វេលាម៉ោង៩:៣០ នាទីព្រឹកថ្ងៃចន្ទ ៦រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

មូលនិធិជនពិការ

**ជួរ រតនៈ**

**ចម្លងជូន**
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)*
*-អង្គភាពប្រឆាំងអំពើពុករលួយ*
*-ឯកសារ-កាលប្បវត្តិ*


សូមទាក់ទង
ទូរស័ព្ទលេខ: ០២៣ ៩៨២ ៣០៦